**Declassified to Public**
**06 September 2012**



D07139
TSL

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception):
....../....../......
ម៉ោង (Time/Heure) : 26-Jun-2009, 14:13
Chanthan Phok

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date /Date de certification):
26-Jun-2009
Chanthan Phok

ភ្នំពេញថ្ងៃទី [illegible] កក្កដា ១៩៧៩

នៅប្រទេសនូវែល សេឡង់ ដើម្បីនិងធ្វើជាមន្ត្រីសេ អ៊ី អា ភ្នាក់ងា ម្នាក់ត្រូវទៅរៀននៅវិទ្យាល័យយោធាពីតម៉ុនPiedmont Military Col. ដែលភ្ជាប់ទៅនិងមូលដ្ឋានសិកនេរ៉េ ហេរ៉េ Here-Here នៅទីនេះសិក្សាកាមអាចប្រើប្រួលឧបករណ៍សិក្សា របស់ចន្ទាយ ហេរ៉េ-ហេរ៉េ ។ ចេះច្បាប់នាយទាហាន ហើយនិងចេះបញ្ជា ។ នៅវិទ្យាល័យពីតម៉ុនក្នុងឆ្នាំទី មួយ ខ្ញុំរៀនល្អប្រសើរពីមុខវិជ្ជាទូទៅ សំរាប់នាយទាហាន ពីព្រោះនៅក្នុងឆ្នាំនេះ ខ្ញុំមិនអាចរើសយកឯកទេសបានភ្លាមទេ ។ នៅឆ្នាំទី ពី - និស្សិតត្រូវរើសយកឯកទេស នៅក្នុងផ្នែក ពិកហ៊ិនយោធាដែលម្នាក់ចូលចិត្ត ។

ខ្ញុំឈ្មោះខែររី ហ្សក ហាមិល Kerry George Hamill បានទៅរៀននៅវិទ្យាល័យយោធាពីតម៉ុន នៅឆ្នាំ ១៩៦៩និង១៩៧០ ។

នៅក្នុងឆ្នាំ ១៩៦៩ ខ្ញុំបានរៀនអំពីក្បួនច្បាប់នៃសង្គ្រាមផ្សេងៗ អំពីក្នុងតាបដើម្បីសំរាប់បើកហាងបន្លំផ្សេងៗ អាកប្បកិរិយាពេលប្រតិបត្តិការ គណិតសាស្ត្រ ហើយពិសេស មុខវិជ្ជាខាងផ្នែកការពារអាយុជីវិតផ្ទាល់ ។ ខ្ញុំជ្រើសរើសមុខវិជ្ជាអំពីក្បួនច្បាប់នៃសង្គ្រាម ហើយនិងគណិតសាស្ត្រពីព្រោះជាការ ចូលចិត្តរបស់ខ្ញុំផ្ទាល់ ។ ឯចំពោះមុខវិជ្ជាឯទៀតៗ ខ្ញុំរៀនគ្រាន់តែឱ្យចេះ ពុសំរាប់ពេលត្រូវការដ៏ថ្មប្រកាយប៉ុណ្ណោះ ។ អ្នកដែលបង្រៀនក្បួនច្បាប់នៃសង្គ្រាមគឺជាសាស្ត្រាចារ្យឯកទេស ម្នាក់ដែលមកពីសកលវិទ្យាល័យវ៉ាយកា តូ

- The University of Waikato ខ្ញុំរៀនសូត្រអំពីសង្គ្រាម ធំៗ អំពីរបៀបប្រយុទ្ធគ្នា អំពីការរីកលូតលាស់នៃអាវុធចាប់ពីសម័យថ្មរលីង រហូត ដល់គ្រាប់បែកអ៊ីដ្រូសែន Hydrogen Bomb ។ គ្រូបង្រៀនឈ្មោះ ម៉េសុន Mason អ្នកដែលបង្រៀនគណិតសាស្ត្រជាអតីតមន្ត្រីលេអ៊ីអា - ម្នាក់ដែលកើតនៅប្រទេសនូវែលសេឡង់ ឈ្មោះលក្ខិ ៣ ដុដ Dodds - គាត់ជាអ្នកជ្រើសរើស បុគ្គលិកឱ្យលេ អុី អា នៅពីក មុន និងមៀរី - មៀរីទី ២ គាត់ក៏បង្រៀនគណិតសាស្ត្រនៅវិក្យនោះដែរ ។ នៅក្នុងផ្នែកគណិតសាស្ត្រ មានការរៀនសូត្រមួយយ៉ាងល្អិតល្អន់ អំពីការបាញ់កាំភ្លើង ។ ដុដ ជាអ្នកបង្រៀនឱ្យចេះកាន់បញ្ជីគិតគូរលេខរបៀបក្នុងធនាគារ ។ មុខវិជ្ជានេះសំខាន់ណាស់ចំពោះមន្ត្រីលេ អុី អា ពីព្រោះគេអាចត្រូវការទៅនៅពេលណា ដែលត្រូវបើកហាងលក់ស៊ីដើម្បីបន្លំលាក់មុខងារពិតប្រាកដ ។ ចំពោះមុខវិជ្ជានេះ មានតែការអនុវត្តទេ គ្មានទ្រឹស្តីទេ មានតែរបៀបប្រើប្រាស់លេខប៉ុណ្ណោះ ។

មុខវិជ្ជាខាងផ្នែក អាកប្បកិរិយា ពេលប្រតិបត្តិការ គឺជាការរៀនសូត្រនិយាយគ្រលពូតែប៉ុណ្ណោះ ។ គេបង្រៀនអំពីទ្រឹស្តីធំៗខាងផ្នែកចិត្តសាស្ត្រ - ហើយនិងអាកប្បកិរិយារបស់សត្វ អាកប្បកិរិយារបស់អ្នកនិយការយើ ។ គ្រូបង្រៀនឈ្មោះប៉ិបពែរ Pepper គឺជាសាស្ត្រាចារ្យមកពីសកលវិទ្យាល័យ វ៉ាយកាតូ ។ ខ្ញុំអត់មានចេះអ្វីច្រើនពីមុខវិជ្ជានេះទេ វាគ្រាន់តែ - ជាលំនាំដើមសំរាប់មុខវិជ្ជានៅឆ្នាំទីពីរ ។

នៅក្នុងមុខវិជ្ជានៃឆ្នាំទីមួយ មានការបង្រៀនអំពីការខិតខំ ការពារកាយជីវិតផ្ទាល់ ដែលជាមុខវិជ្ជាសំខាន់ជាងគេបង្អស់ ។ និស្សិតនិមួយៗ មិនហ៊ានខានទេពេលដែលត្រូវរៀនមុខវិជ្ជានេះ ។ អ្នកបង្ហាត់ក្បាច់ក្បួន ជា

Extracted from ERN: 00007514-00007589

ទាហានដោយប្អូនជាន់. Sergent-Major ម្នាក់មកពីបន្ទាយបង្ហាត់ហ្វឹកហ្វឺន ឈ្មោះ ដុនត្រូន Duntroon នៅប្រទេសអូស្ត្រាលី ។ គាត់ឈ្មោះប្រោន Brown ជាទាហានប្អូនជាន់ សេអ៊ីកា មានមុខងារនឹងជ្រើសរើសភ្នាក់ងារ ឱ្យ សេអ៊ីកា នៅប្រទេសអូស្ត្រាលី និងនូវែល ហ្សេឡង់ ។ នៅក្នុង បន្ទាយនោះកន្លងមកនេះ គាត់បានជ្រើសរើសភ្នាក់ងារ សេអ៊ីកា រាប់សិបនាក់ ពីបន្ទាយទាំងពីរទៅឱ្យ សេអ៊ីកា ។ នៅក្នុងមុខវិជ្ជានេះ មានទ្រឹស្តីមួយចំនួន ប៉ុន្តែភ្ជាប់ទៅនឹងទ្រឹស្តីនេះមានការអនុវត្តជាក់ស្តែងជានិច្ច ។ នៅក្នុង ផ្នែកទ្រឹស្តីមាន អំពីការប្រើទឹកមុខ ( Physiology )

អំពីការពន្យារពួលសម្ងំហើយនឹងការចេះប្រើថ្នាំខ្លះ ។ នៅក្នុងការរៀន សូត្រមុខវិជ្ជាការពារអាយុជីវិតនេះ ដំបូងបំផុតគេបង្ហាត់ហ្វឹកហ្វឺនឱ្យចេះលោត ចេះផ្លោះចេះទត់ល្បឿន ចេះហែលទឹក ហើយនឹងចេះដើរយកចម្ងាយ ។ ខ្ញុំចាប់ធ្វើកម្មសិក្សាដំបូងនៅខែឧសភា ឆ្នាំ ១៩៦៩នៅកោះហ្គ្រេតបារៀ Great Barrier ក្នុងឈូងសមុទ្រហូរ៉ាគី Hauraki Gulf ចំពោះវគ្គសិក្សា នេះម្នាក់ៗទទួលកាបិតមួយ ឈើគូស៤ ឬ ៥ ដើមម្ហូបអាហារសំរាប់៨ថ្ងៃហើយ និង ខោអាវមួយបន្លាស់តែប៉ុណ្ណោះ ។ សិក្ខាកាមទាំងអស់ត្រូវធ្វើជំរំមួយសំរាប់រស់ ឱ្យបានបីអាទិត្យ ។ យើងចែកគ្នាជាពួក ក្នុងមួយពួកៗមាននិស្សិតថ្នាក់ទីមួយប្អូននាក់ ។ និងនិស្សិតថ្នាក់ទីពីរម្នាក់ដែលជាអ្នកដឹកនាំនឹងបញ្ជា ។ យើងត្រូវចេះរៀន ចាប់ត្រី ធ្វើលប ទ្រូ ហើយនឹងធ្វើអន្ទាក់ចាប់សត្វ ។ ត្រូវចេះសំគាល់មើល ដង្កូវឬសឈើ ផ្លែឈើធំនឹងក្រូចដែលអាចហូបបាន ហើយត្រូវចេះដាំស្លទា ។ យើងត្រូវចេះពិសោធន៍លើគ្រឿងដាំស្ល មើលតើវាពុលឬមិនពុល ។ ដើម្បី សំគាល់ថាបន្លែផ្លែឈើណាមួយពុលឬមិនពុល គេធ្វើពិសោធន៍ដូចតទៅ ជាដំបូងយក បន្លែផ្លែឈើនោះទៅលុញលើស្បែក បើកាលណាគ្មានរមាស់ឬក្រហមទេ ត្រូវ យកបន្លែផ្លែឈើនោះមកហិត ។ បើគ្មានខ្លិនចម្លែកអាក្រក់ទេ យកវាទៅក កោសនឹងបបូរមាត់ទៀត បើគ្មានប្រតិកម្មអ្វីគួរឱ្យសង្ស័យទេ នោះត្រូវកោស ស្បែកឱ្យចេញឈាមបន្តិច ហើយយកបន្លែផ្លែឈើមកជូតមើល បើឈាមគ្មានផ្លាស់ប្តូរ

Extracted from ERN: 00007514-00007589

ពេលចម្លែកក្នុងខ្ទះពពុះទទេនោះ ត្រូវយកទាមកខាំញ៉ាំញីរួចខាំបោលរួចចង់ចាំ ១០ នាទីបើគ្មានប្រតិកម្មអ្វីអាក្រក់ទើបចាប់ហូប ប៉ុន្តែល្អបញ្ជាក់ថា ចំពោះបន្លែផ្លែឈើដែលទើបស្គាល់ដំបូងដូច្នេះ ត្រូវហូបបន្តិចម្ដងៗ ការសាកមើលនេះពុលឬមិនពុលនេះ គឺដើម្បីចៀសវាងយើង ៗ ឲ្យមានជំនឿលើខ្លួនឯង ឲ្យចេះសំគាល់មើល ដើមឈើហើយនឹងបន្លែណាដែលអាចហូបបាន ។ យើងត្រូវចេះលង់ទឹក ហើយនឹងលាក់ខ្លួនកុំឲ្យគេមើលពីចម្ងាយឃើញ ។ កម្មសិក្សាទីមួយនេះមានសំណូមពរបង្រៀនឲ្យយើងចេះរស់នៅកន្លែងណាមួយក៏ដោយកុំឲ្យគេសំគាល់ឃើញ ។ កម្មសិក្សាទីពីរ គឺនៅខែកក្កដា ឆ្នាំ ១៩៦៨ ។ ម្ដងនេះគេយកយើងទៅដាក់ចោលនៅអូរ៉ាវេរ៉ាណាស្យូណាល់ប៉ាក Urawera National Park មានទាំងផែនទីត្រីវិស័យ ហើយនឹងម្ហូបអាហារ ។ យើងចែកជាពួកម្ដងទៀត មួយពួកមានគ្នាបួននាក់ ប៉ុន្តែម្ដងនេះអត់មានលិខិតនៅថ្នាក់ទីពីរមកណែនាំយើងទេ ។ គោលបំណងនៃកម្មសិក្សានេះ គឺឲ្យយើងចេះរកផ្លូវទៅបន្ទាយរ៉ូតូរូអា Rotorua ឲ្យបានឆាប់បំផុត ហើយកុំឲ្យគេមើលឃើញយើងផង ។

កម្មសិក្សាទីបី គឺនៅក្នុងភ្នំនៃតំបន់សោធើនអាល់ Southern Alps ក្នុងកោះសោធអាយឡិន South Island នៃប្រទេសនូវែលហ្សេឡង់ ក្នុងខែកញ្ញា ឆ្នាំ ១៩៦៨ ។ ម្ដងនេះយើងត្រូវរៀនបច្ចេកទេសឡើងភ្នំនិងដើរលើទឹកកក ។ ត្រូវចេះប្រើខ្សែ ធ្វើចំណងធ្វើតំណខ្សែ ។ល។ គេបង្រៀនឲ្យយើងចេះដំឡើងហើយនឹងប្រើខ្សែរព្រួរឆ្លងពីកន្លែងមួយទៅកន្លែងមួយ —

Extracted from ERN: 00007514-00007589

ទៀត ។ ដូចនេះយើងយល់ថែកគ្នាជាពួកបួននាក់ហើយ ពីព្រោះកន្លែងប្រតិបត្តិការវះព្រោះថ្នាក់ពេក យើងចែកគ្នាជាបីក្រុម ក្នុងមួយក្រុមមាននិស្សិត ៥០ នាក់ ។ កម្មសិក្សាចុងក្រោយបង្អស់ គឺនៅលើស្ទឹង វ៉ង់ហ្គានុយ

Wanganui River នៅខែតុលាឆ្នាំ ១៩៦៩ ។ យើងចែកគ្នាជាក្រុម មួយក្រុមៗមាន ៥០ នាក់ ។ គេចែកទូកឱ្យយើងជិះ ទូកសំរាប់មនុស្សម្នាក់ឬពីរនាក់ ។ ចែកច្បាស់ឲ្យសំរាប់ធ្វើដំណើរហើយនិងកាំភ្លើង ។ យើងត្រូវធ្វើដំណើរតាមដងស្ទឹងរហូតដល់សមុទ្រ ទាំងអស់មានចម្ងាយ ៣០០ម៉ាយប្រហែល ៤៨០គ.ម យើងត្រូវប្រើទូកទៅពេលយប់ហាងអស់ណាស់ចម្ងាយ ១០០ម៉ាយ · ១៦០ គ.ម ។ នៅក្នុងកម្មសិក្សានេះយើងរៀនចែកទូក បញ្ចៀសត្វនៈសាច់តូចធំៗ មកដាំស្ល ។ យើងបញ្ចប់មុខវិជ្ជាផ្នែកការពារអាយុជីវិតផ្ទាល់នៅបន្ទាយ មៀវី - មៀវី ក្នុងខែវិច្ឆិកា ឆ្នាំ ១៩៦៩ ។ គេបង្រៀនឱ្យយើងចេះក្បាច់ការពារខ្លួន ចេះកាត់វង់ចេះវាយតបវិញ ។ គេបង្រៀនឱ្យស្គាល់ចំណុចស្លាប់ នៅក្នុងខ្លួនមនុស្ស ។ល។ គេបង្រៀនឱ្យយើងចេះប្រើកាំភ្លើង រៀនបាញ់វង់ដោយប្រើកាំភ្លើងវែងកាលិប ៣០៣ និងកាំភ្លើងខ្លីកាលិប ៣៨ ។

នៅឆ្នាំ ១៩៧០ ជំនាន់ទីពីរ នៅសាលាពីតមុំ ខ្ញុំត្រូវរើសឯកទេស - ខាងចារកម្ម ។ មានមុខវិជ្ជាពិសេសមួយចំនួនសំរាប់ផ្នែកនេះនៅពីតមុំ ។ ខ្ញុំរើសមុខវិជ្ជាខាងផ្នែកចារកម្មសំរាប់មន្ត្រីដែលមានគ្រូបង្រៀន ម្នាក់ឈ្មោះ រ៉ៅ. Rouse គាត់ជាជនជាតិអាមេរិក ពាក់សក្តិ ៤ សេ អ៊ី អា ។គាត់ត្រូវជ្រើសរើសមើលមន្ត្រីចារកម្មណាដែលគ្រាន់បើជាងគេដើម្បីផ្ញើរឱ្យអ្នកនោះចូលសេ អ៊ី អា ហើយទៅបណ្តុះបណ្តាលនៅអាមេរិចថែមទៀត ។ក្រោយមកទៀត ខ្ញុំក៏ឮសឹងថាអ្នកខ្ញុំស្គាល់គាត់ក្នុងចលនាកិច្ចមុនៗ ។ ខ្ញុំរៀនបច្ចេកទេស

យូរបង្កើយដូចជា ការធ្វើឲ្យអ្នកទោសប្រប់ចូកប្រចាំប្រចាំខែទាំងពេល ប្រចាំ ថ្ងៃ ត្រូវនៃទៀនសូត្រអស់ពីបច្ច័យនៃការផ្លាស់ប្ដូរបុគ្គលការ ជាមួយអ្នកទោស នៃការបង្អត់ដំណេកការធ្វើទុក្ខបុករម្មេញ ។ល។ ទៀនបរប្ចកទេសល្បូរសំនួននិមួយៗ ទៀនសំគាល់អាកប្បកិរិយាអ៊ីមានធម្មតា តើវាមាននៃអ្វីខ្លះ នៅក្នុងកាលៈទេសៈ ផ្សេងៗ ។

នៅក្នុងមុខវិជ្ជាគមនាគមន៍ទូរទៅ មានវិជ្ជាកម្មួយពិសេសសំរាប់មន្ត្រី-ចារកម្ម ។ ខ្ញុំរៀនប្រើប្រាស់វិទ្យុទាក់ទងផ្សេងៗ រៀនអំពីប្រព័ន្ធខាងផ្នែកលោកអាកាស អង់តែន ហើយនិងលេខសញ្ញាមរ៍ស Morse ព្រម ជាមួយនេះខ្ញុំក៏រៀនយ៉ាងល្អិតល្អន់រៀនប្រើនិងរៀនជួសជុលគ្រឿងក្នុងវិទ្យុ ។ គ្រូបង្រៀនឈ្មោះ ពែរហាម Perham ជាសក្តិ ៣ សេ អ៊ី អា នៅក្នុងក្រសួងគមនាគមន៍ របស់ សេអ៊ី អា ដែលប្រើនដែលធ្វើការជាមួយម៉ាស៊ីនប្រាប់ប្រជាជ តាមធម្មតា គាត់រស់នៅឯវ៉ាស៊ីងតោន ឌីស៊ី Washington D.C. ប៉ុន្តែ គាត់មកប្រទេសនូវែល ហេតុនេះ ដើម្បីនិងបង្រៀនជាពិសេសអំពីគ្រឿងក្រៅល្ហាប់និងផ្សាយសំឡេង ល្អិតធ្នារម៉ែនទែន ។ នៅក្នុងគ្រឿងក្រៅពិសេសនោះ មានមាស៊ីនថតសំឡេង មាស៊ីនផ្សាយនិងទទួលសំឡេងល្អិតតូច ហើយនិងប្រដាប់ថតល្អិតតូច ។ ខ្ញុំរៀនប្រើហ្វីលកាំងក្រហម infrared ក៏ដូចជា រៀនប្រើហ្វីលធម្មតាដែលហាមបង្រៀនយើងថែមទៀត ឲ្យចេះប្រើលេខនិងអក្សរសម្ងាត់ ។ បង្រៀនទាំងអស់នេះ ។ ត្រូវចេះប្រើបញ្ជីលារ ដើម្បីយកលេខអក្សរសម្ងាត់មកដែលអត្ថបទធ្វើលារ ហើយយកឯកសារសម្ងាត់មកផ្ទេរៈស្រាយលេខសម្ងាត់វា ដើម្បីបានអត្ថបទទើបវិញ ។ ត្រូវចេះធ្វើឯកសារឲ្យបានប្រើនរបៀបយ៉ាង ។

មានមុខវិជ្ជាមួយទៀតសំរាប់មន្ត្រីចារកម្មដែលនិយាយអំពីការរកលេសធ្វើ

00007521





មីឡូណាក៏មុខពិតប្រាកដ របស់ភ្នាក់ងារ សេ អ៊ី អា ។ គ្រូបង្រៀនឈ្មោះ លិន ឌើរ Sanders ជាលក្ខិណ៍ នៅក្នុងមន្ទីរចារកម្មរបស់ប្រទេសនូវែល ហ្សេឡង់ ។ លិន ឌើរ បញ្ជាក់ប្រាប់អំពីគុណសម្បត្តិនិងគុណវិបត្តិនៃការប្រើ មុខរបរខ្លះ ។ គាត់បញ្ជាក់យ៉ាងល្អិតល្អន់ថា ត្រូវធ្វើដូចម្តេច ដើម្បីដំឡើង - ហាងមួយ ។ ត្រូវចេះធ្វើឈ្មួញធ្វើការហើយនិងចេះប្រើ ទុនដើម្បីឲ្យហាង នេះដើរ បើចង់ត្រូវប្រើហាងរកស៊ីមួយដែលមានផ្លាកឈ្មោះតូចហើយទាក់ទ ងផ្ទាល់ជាមួយនិងសាធារណជន ។

និស្សិតថ្នាក់ទីពីរ ទាំងអស់គ្នាត្រូវរៀននិយាយនៅមុខមហាជន ហើយ មុខ វិជ្ជានេះវាចាំបាច់ខានមិនបានទេ ។ គ្រូបង្រៀនឈ្មោះ អេស តា S. Tarr មកពីវិជ្ជាស្ថាន កាណេជី Carnegie គាត់ជាលក្ខិ ៣ សេ អ៊ី អា ជាចាងហ្វាងមន្ទីរសេ អ៊ី អានៅក្រុងហេមិលតុន Hamilton ឆ្នាំ ១៩៧២ - ៧២ ហើយនិង ១៩៧៣ ខ្ញុំរៀនសលលវិទ្យាល័យវ៉ៃកា តូ . Waikato នៅដើមឆ្នាំ ១៩៧៤ ខ្ញុំទៅធ្វើការនៅមន្ទីរកណ្តាល របស់ សេ អ៊ី អា នៅអូក្លង់ក្នុងប្រទេស នូវែល ហ្សេឡង់ Auckland, New Zealand លក្ខិណ៍ សេ អ៊ី អា ឈ្មោះ រេ ម៉ង ដេវី Raymond . Davies សញ្ជាតិអាមេរិក ជាអ្នកកាន់កាប់មន្ទីរនេះ ហើយជានាយក ធំ បំផុតរបស់សេ អ៊ី អា នៅ នូវែល ហ្សេឡង់ ។ នៅក្នុងរយៈពេល២ខែ បន្ទាប់មក គឺពីខែមករា ឆ្នាំ ១៩៧៤ទៅ ខែសីហាឆ្នាំ ១៩៧៤ ខ្ញុំរៀនអនុវត្ត របៀបរបបធ្វើការងាររបស់សេ អ៊ី អា រៀនចាត់ចែងមន្ទីរហើយនិងរៀន - បញ្ជានៅប្រទេសនូវែល ហ្សេឡង់ សេ អ៊ី អាមានមន្ទីរនៅក្នុងទីក្រុងវ៉ង - ហ្គារ៉ី Whangarei អូក្លង់ Auckland ហេមិលតុន Hamilton រ៉ូតូរូអា Rotorua វ៉ាកាតានី Whakatane

Extracted from ERN: 00007514-00007589

ហ្គិសបិរ៉ឺ Gisborre តូប៉ូ Taupo វ៉ាំងហ្គានូយ Wanganui -
វ៉ិលលីងតោន Wellington ប្លិនហាម Blenham
គ្រីស្ទឆើជ Christchurch ដានឌីឌីន Dundedin និង
វ៉ិសពត៍ Wesport មន្ទីរទាំងអស់នេះផ្សាយទាក់ទងទូរលេខផ្ទាល់ទៅមន្ទីរ
កណ្តាលនៅអូក្លង់ ចំពោះការទាក់ទងប្រញាប់ ៗ នៅប្រទេសនូវែល -
ហ្សេឡង់ សេ អ៊ី អា យកចិត្តទុកដាក់ធ្វើម៉េចឱ្យប្រទេសនេះមានសភាពការណ៍
នយោបាយ និងហិរញ្ញវត្ថុ និងនរ ជាពិសេសដើម្បីការពារទុនរកស៊ីរបស់អាមេរិកៗ
សេ អ៊ី អា សិក្សានយោបាយរដ្ឋ ដោយប្រើវិទ្យុនិងទូរទស្សន៍ជាពិសេស ៗ អ្ន
កគ្រប់គ្រងស្ថានីយទូរទស្សន៍ គិន ហ្សិត វីវី អាយ NZTVI ឈ្មោះពី -
អាលឡិន P.Allen ធ្វើការឱ្យសេ អ៊ី អា ៗ គាត់ផ្សាយតែដំណឹង
ឬផែនការនយោបាយប្រតិកិរិយា ៗ ព្រមជាមួយនេះ អ្នកគ្រប់គ្រងស្ថានីយអិុច
អិុច XX2 នៅទីក្រុងវ៉ិលលីងតុន ឈ្មោះ ជេហ្វាកមើរ J.Farmer
ក៏ធ្វើការឱ្យសេ អ៊ី អារ៉ែវ ៗ គាត់ផ្សាយដំណឹងឱ្យសេ អ៊ី អា ជាង ១០
ឆ្នាំហើយ ហើយមានឥទ្ធិពលខ្លាំងនៅក្នុងចំណោមអ្នកសិក្សានយោបាយ ៗ សេអ៊ី អា
ប្រើមនុស្សរាប់ជួរខ្លះ២ងនៅប្រទេសនូវែល ហ្សេឡង់ ៗ នៅប្រទេស
នូវែល ហ្សេឡង់ ភ្នាក់ងារសេអ៊ី អាភាគច្រើនធ្វើមុខងារជាភ្នាក់ងារប្រតិ
បត្តិការណ៍ ថ្នាក់ទី ៥ a grade five field agent ម្នាក់ៗទទួល ជា
ប្រាក់១២៥០ ដុល្លាក្នុងមួយឆ្នាំ ៗ រួចហើយទើបឡើងជាភ្នាក់ងារទីបួន បានប្រា
ក់មួយខែ ១៥០០ ដុល្លា ក្នុងមួយឆ្នាំ ថ្នាក់ទាំងពីរនេះជាថ្នាក់ទាបមែនទែនហើយ
ពេលវេលាដែលត្រូវបំពេញមុខងារនេះ មិនលើសពីរ ទៅ ២ ខែទេ ៗ
ភ្នាក់ងារប្រតិបត្តិការណ៍ថ្នាក់ទី ៣ ទទួលជាប្រាក់កាល២៥០០ដុល្លាមួយឆ្នាំ ៗ ភ្នាក់
ងារថ្នាក់ទី៣ ត្រូវធ្វើការជាមួយភ្នាក់ងារថ្នាក់ទីមួយ ឬថ្នាក់ទីពីរឬមន្ត្រីថ្នាក់ទាប

00007523





នៅកន្លែងណាក៏ដោយ ភ្នាក់ងារប្រតិបត្តិការលើថ្នាក់ទី ពីទទួលប្រាក់កាលពី ៥០០០ ទៅ ៨០០០ ដុល្លាក្នុងមួយឆ្នាំ ។ ភ្នាក់ងារថ្នាក់ទីពីរនេះធ្វើការដោយឯក-រាជម្ចាស់ការបាន ហើយអាចទៅប្រតិបត្តិការនៅកន្លែងណាក៏ដោយឲ្យតែគេត្រូវការ ។ ភ្នាក់ងារថ្នាក់ទី មួយ ជាអ្នកប្រតិបត្តិការលើអន្តរជាតិ ។ ថ្នាក់នេះ ទទួលបានទៅដល់ ១២០០០ដុល្លាក្នុងមួយឆ្នាំ ។ ភ្នាក់ងារនេះធ្វើការដឹងតែដោយឯកចិត្ត ហើយធ្វើដំណើរទៅជុំវិញពិភពលោក ដោយទទួលបញ្ជាពីទូត ឬកុងស៊ុលអាមេរិកនៅក្នុងប្រទេសនិមួយៗ ។ល មានតែភ្នាក់ងារថ្នាក់ទីមួយនិងថ្នាក់ទីពីរទេ ដែលទទួលកាំភ្លើងខ្លីកាលីប ៣៨ជាស្វ័យប្រវត្តិបាន ។ បើនិយាយឱ្យចំទៅ ភ្នាក់ងារប្រតិបត្តិការលើថ្នាក់ទីមួយ ជាអ្នកបំពេញការងារអន្តរជាតិ ។ បើកាលណាចង់ឡើងសក្តិទៀតនៅក្នុង សេ អ៊ី អា ភ្នាក់ងារនេះត្រូវតែទៅរៀននៅសាលាមន្ត្រី ។ ដំបូងបំផុតគឺចាប់ឡើងពីសក្តិដោយប្តូរជាន់ Sergent-Major ទៅ ប៉ុន្តែប្រាក់ខែចុះមកនៅត្រឹមតែ ១០០០០ ដុល្លាក្នុងមួយឆ្នាំទេរួច រួចហើយទើបភ្នាក់ងារនោះចាប់ផ្តើមរៀន ។ ដល់ពេលឡើងសក្តិក្រោយទៀតភ្នាក់ងារដដែលនេះត្រូវពាក់សក្តិ ៤ក្លាម ឈោតនាំងសក្តិ មួយ សក្តិ ពីសក្តិបី ប្រតិបត្តិការលើគ្នានឹងកណ្តាលបណ្តាញសំងាត់ទេ ។ថ្នាក់ពុមានតែលិខិតមួយនិងរូបថតហើយនិងរូបសំគាល់របស់សេអ៊ីអា នៅលើនោះ ។

ដោយប្តូរជាន់ពាក់សក្តិនៅលើដៃចំពេងញ៉ា គឺជាក្បាលត្រួតបីពណ៌មាសមានខ្សែរផ្លូតពីក្រោម ។ រូបបញ្ជាក់ដោយសំនួរខាងចុងអក្សរបទរបស់វាជាភាសាអង់គ្លេស ។

ចំពោះមន្ត្រីវិញ ត្រូវចាប់ផ្តើមពាក់សក្តិ មួយ ដែលមានខ្សែរផ្លូត មួយ ហើយនិងរង្វង់មួយនៅលើស្មា ទទួលប្រាក់ខែ ១៥០០ ដុល្លាក្នុងមួយឆ្នាំ ។ មន្ត្រីសក្តិ ២ ទទួលប្រាក់ខែ៣០០០ដុល្លាទៅ ៥០០០ ដុល្លាក្នុងមួយឆ្នាំ ទៅតាមមុខងារ។

Extracted from ERN: 00007514-00007589

00007524





មានខ្មែរស្នូតពីរនិងវង្វង់មួយនៅឡើយ ។ មន្ត្រីលក្ខិពីរ ច្រើនតែប្រតិបត្តិការដើរដោយខ្លួនឯងផ្ទាល់នៅក្រោមបញ្ជារបស់លក្ខិ ៣ឬលក្ខិ ៤ ។ ក្រោយ ពីនេះមក គឺលក្ខិ ៣ មានខ្មែរស្នូតបីហើយនិងវង្វង់ពីរ ទទួលប្រាក់ខែ៦០០០ ទៅ ១០០០០ដុល្លាក្នុងមួយឆ្នាំ ។ លក្ខិ៣ អាចទទួលខុសត្រូវចំពោះមន្ទីរតំបន់មួយ តូចហើយមានភ្នាក់ងារមួយក្រុមតូចធ្វើការជាមួយ ។ លក្ខិ៤ទទួលប្រាក់ខែ៨០០០ទៅ ១.២០០០ ដុល្លាក្នុងមួយឆ្នាំមានសញ្ញាសំគាល់នៅលើស្មា ខ្មែរស្នូតបួននិងវង្វង់ បី ។ រួចហើយមានលក្ខិ៥ លក្ខិ ៥ ទទួលប្រាក់ខែ ១០០០០ទៅ២.៥០០០ដុល្លាក្នុងមួយឆ្នាំ។ គឺជាលក្ខិខ្ពស់បំផុតនៅក្នុងសេ អ៊ី អា ចំពោះភ្នាក់ងារបរទេស ដែលមានសញ្ជាតិ អាមេរិក ។ គឺលក្ខិខ្ពស់បំផុតនៅក្រៅប្រទេសអាមេរិក លក្ខិដែលទទួលខុសត្រូវចំពោះប្រតិបត្តិការណ៍នៅក្នុងប្រទេសមួយទាំងមូល ទទួលប្រាក់ខែ១២.៥០០០ដុល្លាក្នុងពេញមួយឆ្នាំ ប៉ុន្តែដែលឪពុកខ្ញុំដែលគ្រប់គ្រងតំបន់មួយដែរតែដោយមានបុគ្គលិកមួយចំនួនតូច ក៏ទទួលប្រាក់ខែ១.២០០០ដុល្លាក្នុងមួយឆ្នាំប៉ុណ្ណោះទេ ។ ដើម្បីនិងឡើងលក្ខិលើសនេះទៅទៀត ត្រូវតែយកសញ្ជាតិអាមេរិក ហើយទៅធ្វើការនៅលេខាធិការសេ អ៊ី អានៅវ៉ាស៊ីនតោន ឌីស៊ី ។ នៅវ៉ាស៊ីនតោន - សេ អ៊ី អា ចែកជាច្រើនក្រសួង ក្រសួងនិមួយៗ មានភ្នាក់ងារនិងភារកិច្ចពិសេស - ផ្ទាល់ ។ ក្រសួងគមនាគមន៍ ទទួលហើយរួចផ្ញើរពត៌មាន ទៅភ្នាក់ងារហើយ និងមន្ទីរទូទាំងសកលលោក ។ នៅក្នុងក្រសួងនេះមានលក្ខិមួយ ជាអ្នកទទួលភារកិច្ចខាងបច្ចេកទេសហើយជាអ្នកបកប្រែ ។ល។

ផ្ងាប់ទៅនិងក្រសួងគមនាគមន៍ មានក្រសួងទទួលពត៌មាន នៅក្នុងក្រសួងនេះពត៌មានណាក៏ដោយត្រូវរក្សាទុក ហើយបញ្ជូនចេញទៅក្រសួងផ្សេងៗទៀត ។ ក្រសួងគមនាគមន៍និងក្រសួងទទួលពត៌មាន គឺជាមជ្ឈមណ្ឌលកម្មរបស់សេ អ៊ី អាមានចាងហ្វាងរងម្នាក់ជាអ្នកទទួលខុសត្រូវ ។ ចាងហ្វាងរងទទួលប្រាក់ខែ១៣៣.០០០ ដុ,

Extracted from ERN: 00007514-00007589

ល្វាក្នុងមួយឆ្នាំ គ្មានរូបសំគាល់គ្មានសញ្ញាអ្វីទេ មានតែលិខិតសំគាល់ដែលបញ្ជាក់ឋានៈប៉ុណ្ណោះ ។

ក្រសួងប្រតិបត្តិការណ៍ទទួលបន្ទុកខាងផ្នែករៀបចំរបៀបកម្មវិធីយោធាល្អិតល្អន់ ។ ឧទាហរណ៍ ក្រសួងនេះរៀបចំបុគ្គលិកតម្លៃប្រាក់កាល ប្រដាប់ប្រដារ ហើយបញ្ជូន-គ្រឿងនេះទៅភ្នាក់ងារ ។ បុគ្គលិកនៅក្រសួងនេះមានពីសក្តិមួយរហូតដល់សក្តិ ៤ និងស្លក្តិ ៥ មានអ្នកខ្លះជាអតីតភ្នាក់ងារប្រតិបត្តិការណ៍ ដែលអាចជួយផ្តល់បទពិសោធន៍ជាច្រើន កន្លែងនេះក៏មានចាងហ្វាងរងម្នាក់ ជាបញ្ជាការដែរ

ក្រសួងស្រាវជ្រាវរបស់សេ អ៊ី អា អត់មានប្រមូលផ្តុំទាំងអស់ទេ ។ ក្រសួងនេះមានកន្លែងពិសោធន៍ចែកពាសពេញសហរដ្ឋអាមេរិក ហើយច្រើនតែ-ភ្ជាប់ទៅមន្ទីរស្រាវជ្រាវ ឯទៀតៗរបស់រដ្ឋាភិបាលដូចជាសកលវិទ្យាល័យជាដើម កន្លែងពិសោធន៍ទាំងនេះទទួលភារកិច្ចផ្នែកប្រឌិត គ្រឿងបរិក្ខារទំនើបពិសេសសំរាប់សេអ៊ី អា ហើយសំខាន់ជាងនេះទៅទៀត ត្រូវធ្វើពិសោធន៍និងតាមដាន-ការស្រាវជ្រាវនៅក្នុងប្រទេសដទៃទៀតដោយប្រើពត៌មានដែលចាប់មកពីភ្នាក់ងារប្រតិបត្តិការណ៍ ។ អ្នកទទួលបន្ទុកចំពោះកន្លែងពិសោធន៍និមួយៗ ជាសក្តិ ៤ ឬសក្តិ ៥ដែលទទួលខុសត្រូវចំពោះចាងហ្វាងរងខ្លួននៅលេខាធិការរងវ៉ាស៊ីងតោន ឌីស៊ី ។ ក្រសួងសំខាន់ជាងគេនៅក្នុងសេ អ៊ី អាគឺក្រសួងចាត់ចែង-ផែនការ នៅក្នុងក្រសួងនេះ មានលេខាធិការជាច្រើនហើយនិងបុគ្គលិកតូចតាចឯទៀត ៗរបៀបរៀបចំចាត់តាំងមានដូចតទៅ :

ជាដំបូងមានគណៈកម្មាធិការមជ្ឈិមមួយ ដែលមាននៅក្នុងនោះចាង-ហ្វាងសេ អ៊ី អា ចាងហ្វាងរងផ្នែកចាត់ចែងផែនការ - ស្រាវជ្រាវ ។ គមនាគមន៍ - ទទួលពត៌មាន ព្រមជាមួយគ្នានេះមានកម្មាភិបាលមកពីក្រសួងរដ្ឋ ក្រសួងការបរទេស ក្រសួងការពារប្រទេស ក្រសួងហិរញ្ញវត្ថុហើយនិងទីប្រឹ

Extracted from ERN: 00007514-00007589

00007526





យោធាប្រធានាធិបតីម្នាក់ អ្នកទាំងអស់នេះរៀបចំផែនការនយោបាយទូទៅរបស់ លេ អ៊ី អា នៅក្នុងតំបន់និមួយៗ ។ កាលណាចាត់ចែងផែនការនយោបាយ រួចហើយ នោះបង្កើតកម្មាធិការមួយថ្មីទៀតដែលមានចាងហ្វាង ចាងហ្វាងរង ហើយនិងអ្នកជំនាញការខាងផ្នែកបច្ចេកទេសឬខាងផ្នែកនយោបាយតាមសេចក្តីត្រូវការ អ្នកទាំងអស់នេះត្រួតពិនិត្យ កែលំអរួចស្នើរចអនុញ្ញាត ឬមិនអនុញ្ញាតផែនការ-និមួយៗដែលក្រសួងចាត់ចែងផែនការបានរៀបចំឡើង ។ នៅក្នុងក្រសួងចាត់ចែងផែនការ ជាទូទៅនាយកនិងលេខាធិការ មានសក្តិ ៣ និងសក្តិ ៤ ជាច្រើនដែលអ្នកឯកទេសខាងផ្នែកសិក្សានយោបាយនិងចារកម្ម ។ រួចហើយមានសក្តិ ៥មួយចំនួនទៀត ដែលធ្លាប់ធ្វើជាភ្នាក់ងារប្រតិបត្តិការហើយ ហើយត្រូវជួយពិនិត្យមើលថាតើផែនការនោះវាអនុវត្តបានឬទេ ។

ចាងហ្វាងលេ អ៊ី អាទទួលប្រាក់កាល១០.០០០ ដុល្លាក្នុងមួយឆ្នាំ ។ អ្នកនោះទទួលខុសត្រូវចំពោះភ្នាក់ងារ ឬសកម្មភាពណាមួយរបស់ លេ អ៊ី អា ហើយរាយការណ៍ផ្ទាល់ទៅប្រធានាធិបតីនៃសហរដ្ឋអាមេរិក ។ ដោយប្រើបុគ្គលិកផ្ទាល់ខ្លួនមួយចំនួនតូច ជាអ្នកជំនួយហើយនិងលេខាធិការ ចាងហ្វាងលេ អ៊ី អាត្រួតពិនិត្យហើយនិងណែនាំសព្វប្រតិបត្តិការហ្នឹង រវាងក្រសួងទាំងអស់ ។

អ្នកជំនួយការនៅក្នុងលេ អ៊ី អាគ្មានឯកឈ្មោះទេ ។ អ្នកទាំងអស់នេះទទួលប្រាក់កាល ១០០០ ទៅ១៥.០០០ ដុល្លាក្នុងមួយឆ្នាំ ។ លេខាធិការក៏គ្មានឯកឈ្មោះដែរ ហើយទទួលលុយពី៥០០០ទៅ១០.០០០ ដុល្លាក្នុងមួយឆ្នាំ ។

នេះជារបៀបរៀបចំចាត់តាំងជាទូទៅរបស់លេ អ៊ី អា ។

ដោយប្រើអង្គការនេះ រដ្ឋាភិបាលអាមេរិកងាយស្រួលនិងត្រួតពិនិត្យៗរដ្ឋាភិបាលដទៃទៀត ។ ងាយស្រួលនិងធ្វើការលួកបាន់ ឬតំរាមគំរាងដើម្បីនិងយកពត៌មាន ឬជំរុញឲ្យធ្វើសកម្មភាពណាមួយ ។ សភាពការណ៍នេះកើតឡើង-

Extracted from ERN: 00007514-00007589

នៅប្រទេសអូស្ត្រាលី នៅ ឆ្នាំ ១៩៧៥ ។

លក្ខិ ៥ ទេ អ៊ី ហា ឈ្មោះម៉ាក់ស៊ិល ឡំប៊ែរ Maxwell Lambert ។ ដែលប្រតិបត្តិការនៅទីក្រុងស៊ីត នី Sydney បានដឹងថានារីចាស់ នី មូរ៉ូស៊ី Junnie Morosey ដែលជាលេខាធិការរបស់រដ្ឋមន្ត្រី - ក្រសួងហិរញ្ញវត្ថុហើយនិងឈ្មោះ ជិម ខែន Jim Cairns រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ មានការទាក់ទងស្រឡាញ់គ្នារហូតបានខ្លួនប្រាណ នៅពេលនោះ សកម្មរបស់ម៉ាក់ ស៊ិល ឡំប៊ែរនឹងធ្វើឲ្យខូចកិត្តិយសបក្សពលកម្ម The Labour Party ដែលមានលោក វិតឡាម Gough Whitlam ជាមេដឹកនាំនោះនៅកាន់អំណាចតទៅទៀត កាលនោះរដ្ឋាភិបាលអូស្ត្រាលី រៀបចំធ្វើឡើងដោយគណៈបក្សពលកម្ម ។ ដល់បានដឹងនោះភ្លាមគាត់ក៏ឆ្លៀតឱកាសនោះ ដើម្បីនឹងរកពត៌មានណាមួយដែលអាចនិងបំពាល់ដល់បក្សពលកម្ម ។ ម៉ាក់ ស៊ិលក៏ទៅជួបនារីមូរ៉ូស៊ីហើយសំរាយក៏ដែងនារីនោះថានឹងបកអាក្រាតអំពីរឿងរ៉ាវអាភាសជាមួយខែន បើសិនជានារីនោះមិនអនុញ្ញាតឲ្យគាត់មើលបញ្ជីថវិកានិងឯកសាររបស់ខែនទេ ។ ពេលនោះម៉ាក់ ស៊ិលក៏រកឃើញពត៌មានដែលគាត់ចង់បានភ្លាម ។ បញ្ហាត ខែនបានធ្វើការចរចារជាសម្ងាត់ជាមួយនិងរដ្ឋាភិបាលនៃប្រទេសអារ៉ាប់ សេអ៊ូឌិត Saudi Arabia ដើម្បីនិងខ្ចីលុយ ២០០០លានដុល្លារសំរាប់ស្រង់ការខ្វះខាតខ្លាំងក្នុងថវិកា ។ ការខ្ចីលុយនេះ - វាផ្ទុយស្រឡះពីនយោបាយរបស់បក្សពលកម្ម ដែលបក្សនេះបានអះអាងពេលឃោសនាបោះឆ្នោត ។ គ្មានអ្នកណាមួយនៅក្នុងរដ្ឋាភិបាលនេះ បានដឹងរឿងនេះទេទាំងរដ្ឋមន្ត្រីទីមួយ ក៏ដូចរដ្ឋមន្ត្រីឯទៀតៗដែរ ម៉ាក់ ស៊ិលក៏បញ្ជូនរូបថតនៃឯកសារសម្ងាត់នោះ » គាត់បានថតឯកសារនោះ » ទៅកាសែតអូស្ត្រាលីធំៗ បណ្ដាលខែនប្រកែកមិនព្រមទទួលស្គាល់រឿងនេះទេ ប៉ុន្តែនៅពេលដែល

00007528

E2/87.6



ការទាក់ទងគាត់ជាមួយនារីម្នាក់រូបស្រីលេចធ្លោយកទៅក្រៅ គាត់ក៏ចាកចេញពីដំណែង ឯគាត់ភ្លាមទៅ ។ ការបកអាក្រាតសីអាមាំរបស់ បណ្ដាលឱ្យខូចឈ្មោះដល់រដ្ឋាភិបាលទាំងមូល នាំឱ្យគេលែងទុកចិត្តអស់ ។ ការបាត់បង់បណ្ឌិត ដែលនិងជារដ្ឋមន្ត្រីជំនួញផងដែរទាំងអស់នៅក្នុងរដ្ឋាភិបាលបក្សពលកម្ម បណ្ដាលឱ្យមានគុណវិបត្តមួយធំ ក្នុងការដឹកនាំនយោបាយសេដ្ឋកិច្ចរបស់បក្សនោះ ។ ដល់ពេលញដូច្នេះគណៈបក្សមួយឈ្មោះ The National Party ក៏ទាមទារឱ្យរំលាយរដ្ឋាភិបាលបក្សពលកម្មហើយឱ្យអ្នកដឹកនាំបក្ស The National Party .

ឈ្មោះម៉ាល់កូម ហ្វ្រេស៊ែរ Malcolm Fraser ទើបឡើងធ្វើជារដ្ឋមន្ត្រីបណ្ដោះអាសន្នសិនរហូតដល់មានការបោះឆ្នោតថ្មី ។ នៅពេលបោះឆ្នោតបក្ស The National Party បានជាប់ឆ្នោតយ៉ាងច្រើន ឯបក្សពលកម្មវិញនៅតែងើបមុខមិនរួចដដែល ។

លេ អ៊ី អារ ប្រើមធ្យោបាយគំរាមកំហែងនិងល្បិចកលយ៉ាងដូច្នេះពាសពេ - ញពិភពលោក ។ -

ធ្វើនៅថ្ងៃ១៧ កញ្ញា ១៩៧៨

ថែវរី ហ្យា រេហមិល

Extracted from ERN: 00007514-00007589